រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សៀវភៅណែនាំ
# ស្តីពី
# ពន្ធលើប្រាក់ចំណេញ

ឆ្នាំ ២០១៣

រៀបចំ និង បោះពុម្ពផ្សាយដោយ
អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រក្សាសិទ្ធិគ្រប់បែបយ៉ាង

| មាតិកា | ទំព័រ |
|---|---|
| តើពន្ធលើប្រាក់ចំណេញជាអ្វី? | ១ |
| តើមានលក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីសម្រាប់ពន្ធនេះឬទេ? | ១ |
| តើនរណាជាអ្នកជាប់ពន្ធនិវាសនជន? | ១ |
| តើនរណាជាអ្នកជាប់ពន្ធអនិវាសនជន? | ២ |
| តើប្រភពចំណូលត្រូវបានកំណត់យ៉ាងដូចម្តេច? | ២ |
| តើពន្ធនេះអនុវត្តលើរបបកំណត់ពន្ធអ្វីខ្លះ? | ៣ |
| តើឆ្នាំជាប់ពន្ធអ្វីដែលត្រូវប្រើ? | ៥ |
| តើវិធីសាស្ត្រគណនេយ្យអ្វីត្រូវប្រើ? | ៥ |
| តើត្រូវប្រើប្រាស់អត្រាប្តូរប្រាក់អ្វី សម្រាប់ការទូទាត់ជាប្រាក់ដុល្លារសហរដ្ឋអាមេរិក? | ៦ |
| តើអ្វីជាប្រាក់ចំណេញជាប់ពន្ធ? | ៦ |
| តើប្រាក់ចំណូលអ្វីខ្លះដែលមិនជាប់ពន្ធលើប្រាក់ចំណេញ? | ៧ |
| តើមានការអនុញ្ញាតឲ្យធ្វើការកាត់កងអ្វីខ្លះ? | ៧ |
| តើត្រូវគណនាការរំលស់យ៉ាងដូចម្តេច? | ៨ |
| តើត្រូវគណនារំលស់ធនធានធម្មជាតិយ៉ាងដូចម្តេច? | ១២ |
| តើការកាត់កងអ្វីខ្លះ ដែលមិនត្រូវបានអនុញ្ញាត? | ១៣ |
| តើពន្ធលើប្រាក់ចំណេញត្រូវគណនាយ៉ាងដូចម្តេច? | ១៤ |
| តើឥណទានពន្ធអ្វីខ្លះ ដែលអាចទាមទារ? | ១៥ |
| តើពន្ធអប្បបរមាជាអ្វី? | ១៧ |
| តើត្រូវដាក់លិខិតប្រកាសពន្ធ និងត្រូវបង់ពន្ធនៅពេលណា? | ១៨ |
| ទោសទណ្ឌ | ១៩ |
| ចុះបើអាជីវកម្មរបស់ខ្ញុំជាប់ពន្ធរបបម៉ៅការ? | ១៩ |
| សំណួរ | ២០ |
| អាសយដ្ឋានទំនាក់ទំនង | ២០ |

## តើពន្ធលើប្រាក់ចំណេញជាអ្វី?

ពន្ធលើប្រាក់ចំណេញគឺជាពន្ធគិតលើប្រាក់ចំណេញជាប់ពន្ធ (ដូចមានពន្យល់នៅទំព័រ១ និង២) របស់៖

- អ្នកជាប់ពន្ធនិវាសនជនចំពោះចំណូលប្រភពកម្ពុជា និងបរទេស
- អ្នកជាប់ពន្ធអនិវាសនជនចំពោះចំណូលប្រភពកម្ពុជា។

## តើមានលក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីសម្រាប់ពន្ធនេះឬទេ?

អ្នកជាប់ពន្ធដែលត្រូវបង់ពន្ធលើប្រាក់ចំណេញត្រូវចុះបញ្ជីនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ (គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សាខាក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនពហុជាតិ និងសហគ្រាសដទៃទៀត ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១ ០០០លានរៀលឡើងទៅ) ឬសាខាពន្ធដារខេត្ត/សាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ ដែលសហគ្រាសនោះតាំងនៅក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។

## តើនរណាជាអ្នកជាប់ពន្ធនិវាសនជន?

អ្នកជាប់ពន្ធនិវាសនជនគឺជា៖

- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃ នៅក្នុងរយៈពេល ១២ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។
- នីតិបុគ្គល ឬក្រុមអាជីវកម្ម (pass-through) ដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**នីតិបុគ្គល** សំដៅដល់សហគ្រាស ឬអង្គការនានាដែលប្រកបអាជីវកម្ម ទោះបីជាបាន ឬមិនទាន់បានទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។

## តើនរណាជាអ្នកជាប់ពន្ធអនិវាសនជន?
អ្នកជាប់ពន្ធអនិវាសនជនគឺជា៖
- រូបវន្តបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន ប៉ុន្តែទទួលប្រាក់ចំណូលប្រភពកម្ពុជា។
- នីតិបុគ្គល ឬក្រុមអាជីវកម្ម (pass-through) ដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងមានគ្រឹះស្ថានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**គ្រឹះស្ថានអចិន្ត្រៃយ៍** សំដៅដល់៖
- ទីតាំងអាជីវកម្មអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ
- សាខាក្រុមហ៊ុនបរទេស ឬទីភ្នាក់ងារដែលមានទីតាំងក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអ្នកជាប់ពន្ធធ្វើអាជីវកម្មរបស់ខ្លួន ឬ
- សកម្មភាពពាក់ព័ន្ធ ឬការទាក់ទងទាំងឡាយផ្សេងទៀត ដែលអ្នកជាប់ពន្ធចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

## តើប្រភពចំណូលត្រូវបានកំណត់យ៉ាងដូចម្តេច?
ប្រាក់ចំណូលខាងក្រោមត្រូវបានចាត់ទុកជាប្រាក់ចំណូលប្រភពកម្ពុជា៖
- ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ឬក្រុមអាជីវកម្មនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន
- ប្រាក់ចំណូលពីការធ្វើអាជីវកម្ម ឬសេវាកម្មដែលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ប្រាក់ចំណូលពីការគ្រប់គ្រង និងសេវាបច្ចេកទេសដែលបានទូទាត់ដោយបុគ្គលនិវាសនជន

- ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យ ឬអចលនទ្រព្យ ដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបីដែលបានទូទាត់ដោយបុគ្គលនិវាសនជន ឬបុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផលចំណេញពីការលក់អចលនទ្រព្យ ឬពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផលចំណេញពីការលក់អចលនទ្រព្យដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បុព្វលាភបានពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំណូលទាំងឡាយណាដែលមិនត្រូវបានចាត់ទុក ថាជាចំណូលប្រភពកម្ពុជា គឺចាត់ទុកថាជាចំណូលប្រភពបរទេស។

## តើពន្ធនេះអនុវត្តលើរបបកំណត់ពន្ធអ្វីខ្លះ?

វិធានសម្រាប់កំណត់ពន្ធលើប្រាក់ចំណេញ មានលក្ខណៈខុសៗគ្នាអាស្រ័យលើរបបកំណត់ពន្ធ។ បច្ចុប្បន្ន របបកំណត់ពន្ធចំនួនពីរត្រូវបានអនុវត្ត គឺរបបពិត (របបស្វ័យប្រកាស) និងរបបមៅការ។

អ្នកជាប់ពន្ធរបបពិត រួមមាន៖

- នីតិបុគ្គល (សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គល គឺត្រូវជាប់ពន្ធតាមរបបពិត ទោះបីសហគ្រាសនោះមានសកម្មភាពអាជីវកម្មប្រភេទអ្វី ឬកម្រិតផលរបរប៉ុន្មានក៏ដោយ។ សហគ្រាសទាំងនេះមាន ជាអាទិ៍ សហគ្រាសរដ្ឋ ក្រុមហ៊ុនចំរុះ ក្រុមហ៊ុនឯកជនសម្ព័ន្ធភាពសាធារណៈ ឬអង្គការឯកជនដែលធ្វើសកម្មភាពស្វែងរកចំណេញ ឬដែលទទួលប្រាក់ចំណូលពីបេតិកភ័ណ្ឌខ្លួន...។)
- សហគ្រាសឯកបុគ្គល (Sole Proprietorship) ដែលអាចជាក្រុមហ៊ុននាំចូល ឬ ក្រុមហ៊ុននាំចេញ
- សហគ្រាសឯកបុគ្គលដែលត្រូវបានទទួលស្គាល់ និងចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត
- សហគ្រាសឯកបុគ្គលដែលទទួលបានកម្រិតផលរបរអប្បបរមាយ៉ាងហោចណាស់មួយ ក្នុងចំណោមកម្រិតផលរបរមួយចំនួនខាងក្រោម [ដោយរួមបញ្ចូលទាំងប្រាក់ពន្ធទាំងអស់ដែលពាក់ព័ន្ធនឹងអាជីវកម្មដែលប្រមូលបាន]៖
  - ប្រាក់ចំណូលដែលបានពីការផ្គត់ផ្គង់ទំនិញ ឬការផ្គត់ផ្គង់ចំរុះទាំងទំនិញ និងសេវាកម្ម ៖ ចាប់ពី៥០០លានរៀលឡើងទៅ ក្នុង១ឆ្នាំ (ឬ ១២៥លានរៀល សម្រាប់រយៈពេល៣ខែជាប់គ្នាណាមួយ)។
  - ប្រាក់ចំណូលដែលបានពីការផ្គត់ផ្គង់សេវា៖ ចាប់ពី ២៥០លានរៀលឡើងទៅ ក្នុង១ឆ្នាំ (ឬ ៦០លានរៀល សម្រាប់រយៈពេល ៣ខែ ជាប់គ្នាណាមួយ)។
  - ប្រាក់ចំណូលដែលបានពីកិច្ចសន្យារដ្ឋាភិបាល៖ ចាប់ពី១២៥លានរៀលឡើងទៅ ក្នុង ១ឆ្នាំ (ឬ ៣០លានរៀល សម្រាប់រយៈពេល ៣ខែ ជាប់គ្នាណាមួយ)។

ផលរបរផ្អែកលើចំនួនជាក់ស្តែង ប៉ុន្តែក៏អាចអនុវត្តបានលើចំនួនប៉ាន់ប្រមាណផងដែរ សម្រាប់សហគ្រាសឯកបុគ្គលថ្មី និងចំនួនប៉ាន់ប្រមាណក្នុងរយៈពេល ៣ខែជាប់គ្នានៃការចាប់ផ្តើម។

វិធាននៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ អនុវត្តតែចំពោះអ្នកជាប់ពន្ធតាមរបបពិតប៉ុណ្ណោះ។

## តើឆ្នាំជាប់ពន្ធអ្វីដែលត្រូវប្រើ?

ឆ្នាំជាប់ពន្ធដែលត្រូវប្រើសម្រាប់កំណត់ពន្ធលើប្រាក់ចំណេញ គឺឆ្នាំប្រតិទិន។ ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុនមេក្រៅប្រទេសដែលគ្រប់គ្រងលើសហគ្រាសកម្ពុជាយ៉ាងហោចណាស់ ៥១% អាចសុំការអនុញ្ញាតប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីនេះ។ សម្រាប់ព័ត៌មានលម្អិត សូមមើលប្រកាសលេខ ១៥៨១ សហវ.ប្រក.ពដ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## តើវិធីសាស្ត្រគណនេយ្យអ្វីដែលត្រូវប្រើ?

អ្នកជាប់ពន្ធត្រូវប្រើវិធីសាស្ត្រគណនេយ្យបង្គរ។ នៅក្នុងវិធីសាស្ត្រគណនេយ្យបង្គរ ចំណូលត្រូវតែរាយការណ៍នៅក្នុងឆ្នាំដែលរកបានចំណូលនោះ បើទោះជាចំណូលនោះទទួលបានការទូទាត់នៅក្នុងឆ្នាំដដែលនោះ ឬ ក៏អត់នោះទេ។ ចំណាយត្រូវបានកាត់កងដោយផ្អែកលើសក្ខីបត្រទាំងអស់ពាក់ព័ន្ធទៅនឹងបំណុល (Liability) របស់អ្នកជាប់ពន្ធសកម្មភាពសេដ្ឋកិច្ចទាក់ទងនឹងចំណាយបានកើតឡើង ហើយចំនួនបំណុលរបស់អ្នកជាប់ពន្ធអាចកំណត់បានដោយភាពប្រាកដប្រជា។

## តើត្រូវប្រើប្រាស់អត្រាប្តូរប្រាក់អ្វី សម្រាប់ការទូទាត់ជាប្រាក់ដុល្លារសហរដ្ឋអាមេរិក?

អគ្គនាយកដ្ឋានពន្ធដារបោះពុម្ពផ្សាយអំពីអត្រាប្តូរប្រាក់ជាផ្លូវការ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនេះ។ អ្នកជាប់ពន្ធត្រូវកត់ត្រាប្រតិបត្តិការដែលធ្វើឡើងជាដុល្លារសហរដ្ឋអាមេរិក នៅក្នុងបញ្ជិកាគណនេយ្យរបស់ខ្លួន ជាប្រាក់រៀល ដោយប្រើប្រាស់អត្រាប្តូរប្រាក់ដែលមានប្រសិទ្ធភាពនៅកាលបរិច្ឆេទ នៃប្រតិបត្តិការនោះ (កាលបរិច្ឆេទចេញវិក្កយបត្រ ឬកាលបរិច្ឆេទនៃការទូទាត់ប្រាក់ជាមុន ឬការបង់ជាដំណាក់កាល)។

ចំពោះសេចក្តីលម្អិត សូមចូលទៅមើលកថាខណ្ឌ២ ផ្នែក ២.៤ ក្នុងប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ (ប្រកាសលេខ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។

## តើអ្វីជាប្រាក់ចំណេញជាប់ពន្ធ?

ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញដុលទទួលបានពីអាជីវកម្ម ដកនឹងការកាត់កងដែលបានអនុញ្ញាត។ ប្រាក់ចំណេញទាំងនេះ រួមមាន៖

- លទ្ធផលនៃប្រតិបត្តិការអាជីវកម្ម [ប្រាក់ចំណេញពីអាជីវកម្ម] ឬ [តម្លៃលើសអាជីវកម្ម] (Business Capital Gain)។
- តម្លៃលើសបានពីអចលនទ្រព្យ (Capital Gain from immovable propreties) ទ្រព្យហិរញ្ញវត្ថុ (Financial Properties) និងទ្រព្យវិនិយោគ (Investment Properties) ដែលទទួលបានពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម។
- ចំណូលពីប្រតិបត្តិការហិរញ្ញវត្ថុ ឬវិនិយោគ។
- ចំណូលពីការប្រាក់ ថ្លៃឈ្នួល និងប្រាក់សួយសារ។

ចំពោះចំណូលពីប្រតិបត្តិការនៃក្រុមអាជីវកម្ម (pass-through) សមាជិកម្នាក់ៗត្រូវបញ្ចូលចំណែកនៃប្រាក់ចំណូល ប្រាក់ចំណេញ ការ

ខាតបង់ ការកាត់កង ឥណទាន និងវិភាគទានសប្បុរសធម៌ដែលបានបែងចែករបស់ខ្លួនដោយឡែកៗពីគ្នាក្នុងរយៈពេលមួយឆ្នាំ (ទោះបីជាមិនត្រូវបានបែងចែកក៏ដោយ)។

## តើប្រាក់ចំណូលអ្វីខ្លះដែលមិនជាប់ពន្ធលើប្រាក់ចំណេញ?

ចំណូលខាងក្រោមនេះត្រូវបានលើកលែងពន្ធ៖

- ចំណូលរបស់រាជរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាល (លើកលែងស្ថាប័នដំណើរការក្នុងនាមជាអាជីវកម្មស្វែងរកប្រាក់ចំណេញ)។
- ចំណូល (មិនរាប់បញ្ចូលចំណូលអាជីវកម្មដែលមិនពាក់ព័ន្ធ) របស់អង្គការមិនស្វែងរកប្រាក់ចំណេញ ដែលត្រូវបានរៀបចំ និងប្រតិបត្តិ-ការ ដោយឡែកសម្រាប់គោលបំណងខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ (ជាទ្រព្យសម្បត្តិ ឬចំណូលពីប្រតិបត្តិការដែលមិនបម្រើឲ្យផលប្រយោជន៍ឯកជន)។
- ចំណូល (មិនរាប់បញ្ចូលចំណូលអាជីវកម្មដែលមិនពាក់ព័ន្ធ) របស់អង្គការពលកម្ម ឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម (ជាទ្រព្យសម្បត្តិ ឬចំណូលពីប្រតិបត្តិការ ដែលមិនមប្រើឲ្យផលប្រយោជន៍ឯកជនរបស់ភាគហ៊ុនិក ឬបុគ្គលផ្ទាល់ខ្លួននោះទេ)។
- ភាគលាភទទួលបានពីសហគ្រាសនិវាសនជនដែលបានបង់ ឬកាត់ពន្ធរួចរាល់តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ។

## តើមានការអនុញ្ញាតឲ្យធ្វើការកាត់កងអ្វីខ្លះ?

ការកាត់កងត្រូវបានអនុញ្ញាតចំពោះ៖

- ចំណាយដែលបានបង្គរក្នុងអំឡុងឆ្នាំជាប់ពន្ធ ដើម្បីដំណើរការអាជីវកម្ម (លុះត្រាមានបញ្ជាក់ច្បាស់លាស់ថា មិនអនុញ្ញាត ដូចការកាត់កងដែលមានពន្យល់នៅទំព័រទី១៥)។

- ចំនួនដែលបានទូទាត់ឲ្យនិយោជិត ប្រធាន សមាជិកនៃក្រុមអាជីវកម្ម សមាជិកគ្រួសារ ឬបុគ្គលដែលពាក់ព័ន្ធនឹងថ្លៃឈ្នួល ការប្រាក់ សំណង ឬប្រាក់ឈ្នួល ប៉ុន្តែតែក្នុងករណីដែលការទូទាត់មានភាពសមហេតុផល និងមានភស្តុតាងបញ្ជាក់ថាពិតជាបានផ្តល់សេវា ផ្តល់ទ្រព្យសម្បត្តិ ឬផ្តល់កម្ចីជាការដោះដូរនឹងការទូទាត់មែន។
- ការរំលស់អគារ និងទ្រព្យសកម្មដទៃទៀត។ សូមមើលចំណុច "តើត្រូវគណនាការរំលស់យ៉ាងដូចម្តេច" នៅទំព័រទី៩។
- ចំណាយការប្រាក់ ប៉ុន្តែមិនត្រូវឲ្យលើសពីចំនួន៖
    - ចំណូលការប្រាក់ និង
    - ៥០% នៃចំណូលសុទ្ធមិនមែនការប្រាក់ (មានន័យថាចំណូលសុទ្ធមុនពេលបូកចំណូលការប្រាក់ និងដកចំណាយការប្រាក់)។

  ចំណាយការប្រាក់ទាំងឡាយណាដែលលើសពីកម្រិតខាងលើត្រូវបន្តទៅឆ្នាំជាប់ពន្ធបន្ទាប់ទៀត។

រំលស់ធនធានធម្មជាតិ (រួមមាន ប្រេង និងឧស្ម័ន)។ សូមមើលចំណុច "តើត្រូវគណនារំលស់ធនធានធម្មជាតិយ៉ាងដូចម្តេច?" នៅទំព័រទី១២។

- វិភាគទានសប្បុរសធម៌ ចំពោះស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនស្វែងរកប្រាក់ចំណេញ ប៉ុន្តែមិនឲ្យលើស៥% នៃប្រាក់ចំណេញជាប់ពន្ធ (មុនពេលធ្វើការកាត់កងវិភាគទានសប្បុរសធម៌នោះ)។
- ការខាតបង់ដែលបន្តពីឆ្នាំជាប់ពន្ធមុន។ ការខាតបង់ពីមួយឆ្នាំមុនអាចបន្តទៅក្នុងឆ្នាំជាប់ពន្ធ ៥ឆ្នាំ បន្ទាប់តែប៉ុណ្ណោះ។

## តើត្រូវគណនាការរំលស់យ៉ាងដូចម្តេច?

ការរំលស់គឺជាចំនួនសរុបនៃ៖

- ការរំលស់ធម្មតា (សូមមើលតារាង នៅទំព័រ៩, ១០, ១១, និងទី១២) រួមទាំង

. ការរំលស់ពិសេសសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្មើនឹង៤០% នៃតម្លៃទ្រព្យរូបី ដែលត្រូវបានប្រើនៅក្នុងការផលិត និងដាក់ឲ្យដំណើរការសេវាក្នុងអំឡុងឆ្នាំជាប់ពន្ធ។ ៤០% នៃការរំលស់ពិសេសអនុវត្តចំពោះតែវិនិយោគិនដែលបានជ្រើសរើសមិនប្រើការលើកលែងពន្ធក្នុងអំឡុងពេលដែលអនុញ្ញាត។ ការរំលស់ពិសេសបន្ថយតម្លៃដែលបានប្រើ ដើម្បីគណនាការរំលស់ធម្មតា។

.

| **វិធីសាស្ត្ររំលស់ស្មើភាគ (Straight-line Method)**<br>**ក្រុមទី១.** អគារ សំណង់ និង រចនាសម្ព័ន្ធមូលដ្ឋានដទៃទៀត | |
|---|---|
| **ជំហានទី១** | គណនាការរំលស់លើទ្រព្យសកម្មនីមួយៗដោយឡែកពីគ្នា។ |
| **ជំហានទី២** | គណនាតម្លៃទ្រព្យសកម្មពីមុន ដោយរួមមានការបូកបន្ថែមចំណាយក្នុងការដាក់ឲ្យដំណើរការក្នុងអាជីវកម្មដែលដាក់ឲ្យប្រើទាំងមុនពេល ឬអំឡុងឆ្នាំជាប់ពន្ធ។* |
| **ជំហានទី៣** | ប្រសិនបើមាន គណនាចំនួនតម្លៃទ្រព្យសកម្មនៅជំហានទី២ ដែលត្រូវបានជម្រះបញ្ជី (Disposed) ក្នុងអំឡុងឆ្នាំជាប់ពន្ធ។ |
| **ជំហានទី៤** | ដកចំនួនដែលបានគណនានៅជំហានទី៣ ចេញពីចំនួនដែលបានគណនាពីជំហានទី២។ |
| **ជំហានទី៥** | គុណចំនួនដែលបានគណនានៅជំហានទី៤ នឹង៥%។ |
| **ជំហានទី៦** | គណនាចំនួនសមតុល្យសេសសល់ចុងក្រោយរបស់ទ្រព្យសកម្ម ដែលមិនទាន់រំលស់ ឬចំនួនដែលបានគណនានៅជំហានទី៥។ នេះគឺជាចំនួនទឹកប្រាក់រំលស់ដែលបានកាត់កងសម្រាប់ទ្រព្យសកម្មនៅក្នុងឆ្នាំជាប់ពន្ធ។ |
| *ប្រសិនបើវិនិយោគិនជ្រើសរើសមិនទទួលយកការលើកលែងពន្ធក្នុងអំឡុងពេលដែលអនុញ្ញាតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់ | |

| |
|---|
| គ្រាន់ ទទួលបានការអនុញ្ញាតឲ្យធ្វើរំលស់ពិសេស៤០% នៃតម្លៃមូលធន នៃទ្រព្យរូបីដែលបានដាក់ឲ្យប្រើប្រាស់ បន្ទាប់មកអនុវត្តតាមការគណនារំលស់ធម្មតា នូវតម្លៃសមតុល្យនៃមូលធនដែលបានធ្វើរំលស់ពិសេស។ |

| **វិធីសាស្ត្ររំលស់ថយជាលំដាប់ (Declining Balance Method)**<br>**ក្រុមទី២** កុំព្យូទ័រ ឧបករណ៍អេឡិចត្រូនិក ឧបករណ៍គ្រប់គ្រងទិន្នន័យ<br>**ក្រុមទី៣** រថយន្ត រថយន្តធុនធ្ងន់ និងគ្រឿងសង្ហារឹម និងសម្ភារៈ<br>**ក្រុមទី៤** ទ្រព្យរូបីផ្សេងៗទៀតទាំងអស់ | |
|---|---|
| **ជំហានទី១** | គណនារំលស់ដោយឡែកពីគ្នា សម្រាប់ថ្នាក់នីមួយៗ ដោយប្រើចំនួនសរុបបញ្ចូលគ្នា ចំពោះទ្រព្យសកម្មទាំងអស់នៅក្នុងថ្នាក់នោះ។ |
| **ជំហានទី២** | គណនាតម្លៃទ្រព្យសកម្មមិនទាន់រំលស់នៅដំណាច់ឆ្នាំជាប់ពន្ធមុន |
| **ជំហានទី៣** | គណនាតម្លៃនៃទ្រព្យសកម្មក្នុងថ្នាក់ដូចគ្នា ដែលទទួលបានមកពីឆ្នាំជាប់ពន្ធមុន។* |
| **ជំហានទី៤** | គណនាចំនួនតម្លៃទ្រព្យសកម្ម ដែលទទួលបានពីការជម្រះបញ្ជីក្នុងថ្នាក់ដូចគ្នាអំឡុងឆ្នាំជាប់ពន្ធ។ |
| **ជំហានទី៥** | ដកចំនួនដែលបានគណនានៅជំហានទី៤ ពីចំនួនសរុបដែលបានគណនានៅជំហានទី២ និងទី៣។ (ប្រសិនបើលទ្ធផលនៃការគណនាខាងលើ ជាសមតុល្យអវិជ្ជមាន ការរំលស់មិនត្រូវបានអនុញ្ញាតឲ្យបន្តទៀតទេ។ ផ្ទុយទៅវិញ ចំនួនដែលស្មើនឹងសមតុល្យអវិជ្ជមាននោះ ត្រូវបានរួមបញ្ចូលទៅក្នុងចំណូល និងចំនួនក្នុងគណនីទ្រព្យសកម្មសម្រាប់ថ្នាក់នេះត្រូវស្មើនឹង"សូន្យ" ។) |
| **ជំហានទី៦** | គុណចំនួនដែលបានគណនានៅជំហានទី៥ នឹង៖ |

| | |
|---|---|
| | • ៥០% សម្រាប់ទ្រព្យថ្នាក់ទី២<br>• ២៥% សម្រាប់ទ្រព្យថ្នាក់ទី៣<br>• ២០% សម្រាប់ទ្រព្យថ្នាក់ទី៤ |
| **ជំហានទី៧** | គណនាចំនួនសមតុល្យសេសសល់ចុងក្រោយរបស់ទ្រព្យសកម្ម ដែលមិនទាន់រំលស់ ឬចំនួនដែលបានគណនានៅជំហានទី៦។ នេះគឺជាចំនួនទឹកប្រាក់រំលស់ដែលបានកាត់កងសម្រាប់ទ្រព្យសកម្មនៅក្នុងឆ្នាំជាប់ ពន្ធ។ |
| *ប្រសិនបើវិនិយោគិនជ្រើសរើសមិនទទួលយកការលើកលែងពន្ធក្នុងអំឡុងពេលដែលអនុញ្ញាតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទទួលបានការអនុញ្ញាតឲ្យធ្វើរំលស់ពិសេស ៤០% នៃតម្លៃមូលធន នៃទ្រព្យរូបីដែលបានដាក់ឲ្យប្រើប្រាស់ បន្ទាប់មកអនុវត្តតាមការគណនារំលស់ធម្មតា នូវតម្លៃសមតុល្យនៃមូលធនដែលបានធ្វើរំលស់ពិសេស។ | |

| | |
|---|---|
| **វិធីសាស្ត្ររំលស់ស្មើភាគ (Straight-line Method)**<br>**ទ្រព្យសកម្មអរូបីទាំងអស់៖** ប្រកាសនីយបត្រ ការរក្សាសិទ្ធិចម្លង គំនូរគំរូ និង សិទ្ធិអាជីវកម្មដែលមានអាយុកាលកំណត់ | |
| **ជំហានទី១** | គណនាការរំលស់ដោយឡែកពីគ្នាសម្រាប់ទ្រព្យសកម្មនីមួយៗ |
| **ជំហានទី២** | គណនាតម្លៃទ្រព្យសកម្មពីមុន ដោយរួមមានការបូកបន្ថែមចំណាយក្នុងការដាក់ឲ្យដំណើរការក្នុងអាជីវកម្ម ដែលដាក់ឲ្យប្រើទាំងមុនពេល ឬអំឡុងឆ្នាំជាប់ពន្ធ។ |
| **ជំហានទី៣** | ប្រសិនបើមាន គណនាចំនួនតម្លៃទ្រព្យសកម្មនៅជំហានទី២ ដែលត្រូវបានជម្រះបញ្ជី ក្នុងអំឡុងឆ្នាំជាប់ពន្ធ។ |
| **ជំហានទី៤** | ដកចំនួនដែលបានគណនានៅជំហានទី៣ ចេញពីចំនួនដែលបានគណនាពីជំហានទី២។ |

| | |
|---|---|
| **ជំហានទី៥** | ចែកចំនួនដែលបានគណនានៅជំហានទី៤ នឹងចំនួនឆ្នាំនៃអាយុកាលរបស់ទ្រព្យសកម្ម។ ប្រសិនបើអាយុកាលនៃទ្រព្យសកម្មមិនអាចកំណត់បានទេ គុណចំនួនដែលបានគណនានៅជំហានទី៤ នឹង១០%។ |
| **ជំហានទី៦** | គណនាចំនួនសមតុល្យសេសសល់ចុងក្រោយរបស់ទ្រព្យសកម្ម ដែលមិនទាន់រំលស់ ឬចំនួនដែលបានគណនានៅជំហានទី៥។ នេះគឺជាចំនួនទឹកប្រាក់រំលស់ដែលបានកាត់កងសម្រាប់ទ្រព្យសកម្មនៅក្នុងឆ្នាំជាប់ពន្ធ។ |

## តើត្រូវគណនារំលស់ធនធានធម្មជាតិយ៉ាងដូចម្ដេច?

| | |
|---|---|
| **ជំហានទី១** | គណនាចំនួនសរុបនៃចំណាយក្នុងការស្វែងរុករក និងអភិវឌ្ឍន៍ (រួមទាំងចំណាយការប្រាក់ ដែលជាប់ទាក់ទងដល់ចំណាយនោះផង) ត្រូវបានបង្ករដើម្បីទាញយកធនធានធម្មជាតិ។ ចំនួននេះត្រូវបូកបញ្ចូល (ធ្វើមូលធនកម្ម) ក្នុងគណនីទ្រព្យសកម្មសម្រាប់ធនធានធម្មជាតិ។ |
| **ជំហានទី២** | គណនាបរិមាណជាក់ស្ដែងនៃធនធានធម្មជាតិដែលបានផលិតក្នុងអំឡុងឆ្នាំជាប់ពន្ធ។ |
| **ជំហានទី៣** | គណនាបរិមាណប៉ាន់ស្មាន នៃអាយុកាលផលិតកម្មធនធានធម្មជាតិសរុប (រួមទាំងចំនួនដែលផលិតបានក្នុងឆ្នាំកន្លងមក)។ |
| **ជំហានទី៤** | ចែកចំនួនដែលបានគណនានៅជំហានទី២ នឹងចំនួនដែលបានគណនានៅជំហាន ទី៣។ |
| **ជំហានទី៥** | គុណចំនួនដែលបានគណនានៅជំហានទី១ នឹងចំនួនដែលបានគណនានៅជំហានទី៤។ នេះគឺជាចំនួនរំលស់ដែលត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំជាប់ពន្ធ។ |

## តើការកាត់កងអ្វីខ្លះដែលមិនត្រូវបានអនុញ្ញាត?

ការកាត់កងមិនត្រូវបានអនុញ្ញាតចំពោះ៖

- ចំណាយលើការកំសាន្ត ការសម្រាកលំហែរ ឬការកំសាន្តនានា។
- វិភាគទាន (ក្រៅពីវិភាគទានសប្បុរសធម៌ចំពោះស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដែលបានបកស្រាយនៅ ទំព័រទី៨) ប្រាក់ជំនួយឥតសំណង និងឧបត្ថម្ភកធន។
- ចំណាយមូលធន (គឺជាមូលធនដែលត្រូវបានប្រើប្រាស់ដើម្បីទទួលបាន ឬកែលម្អទ្រព្យសកម្ម ដូចជាទ្រព្យសម្បត្តិ អាគារ ឬ សម្ភារៈ)។
- ប្រាក់ចំណាយមិនសមហេតុផល។
- ប្រាក់ចំណាយផ្ទាល់ខ្លួន ប្រាក់ចំណាយសម្រាប់ការរស់នៅ ឬប្រាក់ចំណាយក្នុងគ្រួសារ លើកលែងអត្ថប្រយោជន៍បន្ថែមដែលត្រូវបានជាប់ពន្ធកាត់ទុក។
- ប្រាក់ពិន័យ និងទោសទណ្ឌ។
- ពន្ធលើប្រាក់ចំណេញ។
- ពន្ធដទៃទៀតដែលប្រមូលតាមការកាត់ទុក (ដូចជាពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម)។
- ការខាតបង់លើការផ្លាស់ប្តូរ និងការលក់រវាងបុគ្គលដែលពាក់ព័ន្ធមិនថាដោយផ្ទាល់ ឬប្រយោល។ បុគ្គលដែលពាក់ព័ន្ធរួមមាន សមាជិកគ្រួសាររបស់អ្នកជាប់ពន្ធ អ្នកជាប់ពន្ធ (រួមទាំងប្តីប្រពន្ធរបស់ខ្លួន) ដែលគ្រប់គ្រងផលប្រយោជន៍ស្មើចំនួន៥១% ឬច្រើនជាងនេះ ក្នុងសហគ្រាស និងសហគ្រាសដែលគ្រប់គ្រងផលប្រយោជន៍ស្មើចំនួន៥១% ឬច្រើនជាងនេះលើអ្នកជាប់ពន្ធ។
- ចំណាយទាំងឡាយណាដែលមិនទាន់កើតឡើងជាក់ស្តែង (ដូចជាសំវិធានធន) ឬចំណាយដែលអ្នកជាប់ពន្ធមិនអាចបញ្ជាក់នូវបរិមាណ ឬគោលបំណងអាជីវកម្ម។

## **តើពន្ធលើប្រាក់ចំណេញត្រូវគណនាយ៉ាងដូចម្តេច**?

សូមពិនិត្យមើលតារាងទី១ និងទី២ ខាងក្រោម៖

**តារាងទី១**

**ការគណនាពន្ធលើប្រាក់ចំណេញ**

(ប្រាក់ចំណេញប្រចាំឆ្នាំសម្រេចបានដោយ**រូបវន្តបុគ្គល** សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែកចែកឲ្យសមាជិកម្នាក់ៗ របស់ក្រុមអាជីវកម្ម ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល)

| *ភាគនៃប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ (រៀល)* | *ប្រាក់ពន្ធ (រៀល)* |
|---|---|
| 0 – ៦.000.000 | 0 |
| ៦.000.00១ – ១៥.000. 000 | ប្រាក់ចំណេញជាប់ពន្ធ x ៥% – ៣00.000 |
| ១៥.000.00១ – ១0២.000.000 | ប្រាក់ចំណេញជាប់ពន្ធ x ១0%– ១.0៥0.000 |
| ១0២.000.00១– ១៥0.000.000 | ប្រាក់ចំណេញជាប់ពន្ធ x ១៥%– ៦.១៥0.000 |
| ១៥0.000.00១ ឬច្រើនជាងនេះ | ប្រាក់ចំណេញជាប់ពន្ធ x ២0% – ១៣.៦៥0.000 |

**តារាងទី២**

**ការគណនាពន្ធលើប្រាក់ចំណេញ**

(សហគ្រាសនីតិបុគ្គល)

| *ប្រភេទសកម្មភាព* | *ប្រាក់ពន្ធ (រៀល)* |
|---|---|
| គ្រប់សកម្មភាពអាជីវកម្មទាំងអស់ | ២0% នៃប្រាក់ចំណេញជាប់ |

| | |
|---|---|
| លើកលែងតែ គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងអំឡុងពេល លើកលែងពន្ធ កិច្ចសន្យាបែងចែកផលប្រេង ឬឧស្ម័នធម្មជាតិ និងធានារ៉ាប់រង ឬធានារ៉ាប់រងបន្តចំពោះហានិភ័យក្នុងព្រះរាជាណាចក្រកម្ពុជា | ពន្ធប្រចាំឆ្នាំ (ប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិនក្នុងករណីអង្គការមិនស្វែងរកប្រាក់ចំណេញ) |
| គម្រោងវិនិយោគមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងអំឡុងពេលលើកលែងពន្ធ | សូន្យ |
| កិច្ចសន្យាបែងចែកផលប្រេង ឬឧស្ម័នធម្មជាតិ | ៣០% នៃប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ |
| ធានារ៉ាប់រង ឬធានារ៉ាប់រងបន្តចំពោះហានិភ័យក្នុងព្រះរាជាណាចក្រកម្ពុជា | ៥% នៃបុព្វលាភធានារ៉ាប់រងដុល |

## តើឥណទានពន្ធអ្វីខ្លះ ដែលអាចទាមទារ?

## ឥណទានពន្ធបរទេស

អ្នកជាប់ពន្ធនិវាសនជនកម្ពុជាទទួលបានឥណទានពន្ធបរទេសដែលត្រូវបានបង់លើចំណូលប្រភពបរទេស។

ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា នូវប្រាក់ពន្ធបានបង់នៅប្រទេសក្រៅនីមួយៗ និងឯកសារខាងក្រោមនេះ ត្រូវផ្ដល់ជូនអគ្គ-នាយកដ្ឋានពន្ធដារ (នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត-ខណ្ឌដែលគ្រប់គ្រងប្រមូលពន្ធលើសហគ្រាសនោះ)៖

- ឯកសារថតចម្លង (លិខិតប្រកាសពន្ធ និងឯកសារយោង) បញ្ជាក់ពីការបំពេញកាតព្វកិច្ចពន្ធនៅបរទេសនោះ។
- បង្កាន់ដៃពន្ធថតចម្លង បង្ហាញអំពីប្រាក់ពន្ធដែលចេញដោយរដ្ឋបាលសារពន្ធនៅបរទេសនោះ។

ឥណទាននេះគឺចំនួនដែលទាបជាងគេក្នុងចំណោម៖

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ ឬ
- ចំណែកនៃពន្ធប្រាក់ចំណេញកម្ពុជា ដែលបានមកពីប្រាក់ចំណូលប្រភពបរទេស (កំណត់ដោយរូបមន្តដូចខាងក្រោម)។

**ក = ខ x (គ/ឃ)**

**ក៖** ចំណែកនៃពន្ធប្រាក់ចំណេញកម្ពុជាដែលបានមកពីប្រាក់ចំណូលប្រភពបរទេស

**ខ៖** ពន្ធលើប្រាក់ចំណេញកម្ពុជាដែលបានមកពីប្រាក់ចំណូលគ្រប់ប្រភព

**គ៖** ប្រាក់ចំណូលប្រភពបរទេស

**ឃ៖** ប្រាក់ចំណូលគ្រប់ប្រភព

ប្រសិនបើ ឥណទានពន្ធបរទេសលើសពីប្រាក់ពន្ធលើប្រាក់ចំណេញ ចំនួនទឹកប្រាក់ដែលលើសនោះអាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី៥ គិតពីឆ្នាំឥណទានពន្ធនោះបានកើតឡើង។

## ឥណទានពន្ធសម្រាប់ពន្ធកាត់ទុក

ឥណទានពន្ធត្រូវបានអនុញ្ញាតសម្រាប់ពន្ធកាត់ទុកលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធទទួលបានពីការផ្តល់សេវា សួយសារពីទ្រព្យសកម្មអរូបី និងសួយសារពីភាគកម្មក្នុងធនធានរ៉ែ ចំណូលពីការប្រាក់ និងចំណូលពីការជួល។

## ឥណទានពន្ធសម្រាប់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

ឥណទានពន្ធត្រូវបានអនុញ្ញាតចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែដែលបានបង់ ។

## តើពន្ធអប្បបរមាជាអ្វី?

ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ។

ពន្ធអប្បបរមា ត្រូវអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបពិតទាំងអស់ (ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងអំឡុងពេលលើកលែងពន្ធ)។ ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា ១% នៃផលរបរប្រចាំឆ្នាំ (រួមបញ្ចូលទាំងពន្ធ-អាករនានា វៀរលែងអាករលើតម្លៃបន្ថែម) ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។ ពន្ធអប្បបរមាត្រូវបានកាត់បន្ថយដោយបំណុលពន្ធលើប្រាក់ចំណេញ។

ប្រសិនបើ បំណុលពន្ធលើប្រាក់ចំណេញច្រើនជាងពន្ធអប្បបរមា ក្នុងករណីនេះអ្នកជាប់ពន្ធមិនត្រូវជាប់ពន្ធអប្បបរមាទេ។

ប្រសិនបើ បំណុលពន្ធលើប្រាក់ចំណេញតិចជាងពន្ធអប្បបរមា ចំនួនដែលលើសនៃពន្ធអប្បបរមា គឺត្រូវបានទទួលស្គាល់ជាឥណទានពន្ធ ហើយអាចយោងទៅកាត់កងជាមួយប្រាក់រំដោះ ពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់។

***ឧទាហរណ៍៖*** *"ក" ជាសហគ្រាសនីតិបុគ្គលដែលមានផលរបរប្រចាំឆ្នាំ ២៥០.០០០.០០០រៀល និងប្រាក់ចំណេញប្រចាំឆ្នាំ ២០.០០០.០០០រៀល។ សហគ្រាសមានសិទ្ធិទទួលឥណទានពន្ធ ៥០០.០០០រៀល។*

***បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*** *(ពន្ធលើប្រាក់ចំណេញដកឥណទានពន្ធបរទេស) របស់សហគ្រាសត្រូវបានគណនាដូចខាងក្រោម៖*

*(២០.០០០.០០០ X ២០%)–៥០០.០០០*

***= ៣.៥០០.០០០រៀល***

***ពន្ធអប្បបរមា****របស់សហគ្រាស ត្រូវបានគណនាដូចខាងក្រោម៖*

*២៥០.០០០.០០០ X ១%*

***= ២.៥០០.០០០រៀល***

*ដោយសារបំណុលពន្ធលើប្រាក់ចំណេញច្រើនជាងពន្ធអប្បបរមា ដូច្នេះពន្ធត្រូវបង់គឺ ៣.៥០០.០០០ រៀល ជាចំនួនទឹកប្រាក់ដែលធំជាង។ អ្នកជាប់ពន្ធមិនត្រូវជាប់ពន្ធអប្បបរមាទេ។*

## តើត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ពន្ធនៅពេលណា?

## លិខិតប្រកាសពន្ធប្រចាំខែ

ប្រាក់រំដោះពន្ធលើប្រាក់ចំណេញត្រូវប្រកាស និងបង់ក្នុងអត្រា១% នៃផលរបរប្រចាំខែ (រួមបញ្ចូលនូវគ្រប់ប្រភេទពន្ធ-អាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម) ដែលទទួលស្គាល់ជាចំណូលនៅក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ត្រូវបានកត់ត្រាក្នុងទម្រង់លិខិតប្រកាសពន្ធ (Form T01) ដែលត្រូវប្រកាស និងបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ ពីខែដែលបំណុលប្រាក់រំដោះពន្ធលើប្រាក់ចំណេញបានកើតឡើង។

លិខិតប្រកាសប្រាក់រំដោះពន្ធលើប្រាក់ចំណេញតម្រូវឲ្យប្រកាស និងបង់ពន្ធនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ (គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សាខាក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនពហុជាតិ និងសហគ្រាសដទៃទៀតដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១០០០ លានរៀល

ឡើងទៅ) ឬសាខាពន្ធដារខេត្ត/សាខាពន្ធដារ-ខណ្ឌនៃរាជធានីភ្នំពេញ ដែលសហគ្រាសនោះតាំងនៅ ក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។

## លិខិតប្រកាសពន្ធប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវបានកត់ត្រាក្នុងទម្រង់លិខិតប្រកាស (Form TOP 01) ដែលត្រូវប្រកាស និងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹម ៣ខែ បន្ទាប់ពីដំណាច់ឆ្នាំជាប់ពន្ធ (ថ្ងៃទី៣១ ខែមីនា សម្រាប់អ្នកជាប់ពន្ធដែលប្រើប្រាស់ឆ្នាំប្រតិទិន)។

លិខិតប្រកាសពន្ធលើប្រាក់ចំណេញតម្រូវឲ្យប្រកាស និងបង់ពន្ធនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ (គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សាខាក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនពហុជាតិ និង សហគ្រាសដទៃទៀតដែលមានផលរបរចាប់ពី ១០០០ លានរៀលឡើងទៅ) ឬសាខាពន្ធដារខេត្ត/សាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ ដែលសហគ្រាសនោះតាំងនៅ ក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។

## ទោសទណ្ឌ

ការខកខានមិនបានចុះបញ្ជី ឬដាក់លិខិតប្រកាសពន្ធ ឬបង់ពន្ធយឺត អាចត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។

## ចុះបើអាជីវកម្មរបស់ខ្ញុំជាប់ពន្ធតាមរបបម៉ៅការ?

អ្នកជាប់ពន្ធដែលមិនបំពេញតាមលក្ខខណ្ឌ នៃអ្នកជាប់ពន្ធតាមរបបពិត គឺជាអ្នកជាប់ពន្ធតាមរបបម៉ៅការ។ វិធានក្នុងអត្ថបទបោះពុម្ពផ្សាយនេះមិនអនុវត្តលើអ្នកជាប់ពន្ធរបស់ម៉ៅការឡើយ។ ផ្ទុយទៅវិញ អ្នកជាប់ពន្ធទាំងនេះ ត្រូវបង់ពន្ធលើប្រាក់ចំណេញ ដែលបានប៉ាន់ប្រមាណរបស់ខ្លួនជា

ប្រចាំខែ។ សាខាពន្ធដារខេត្ត-ខណ្ឌ កំណត់ចំនួនពន្ធប៉ាន់ប្រមាណ ដែលត្រូវបង់ដោយផ្អែកលើកត្តាផ្សេងៗជាច្រើន។

សម្រាប់ព័ត៌មានលម្អិតស្តីពីការគណនា និងទូទាត់ពន្ធលើប្រាក់ចំណេញសម្រាប់អ្នកជាប់ពន្ធមៅការ សូមមើលសៀវភៅណែនាំស្តីពី "ពន្ធលើប្រាក់ចំណេញ (សម្រាប់អ្នកជាប់ពន្ធរបបមៅការ)។"

## សំណួរ

ប្រសិនបើ អ្នកមានសំណួរដែលមិនមានឆ្លើយនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ សូមរកមើលប្រកាសស្តី ពីពន្ធលើប្រាក់ចំណេញ ប្រកាសលេខ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣។ ជាមួយគ្នានេះផងដែរ អ្នកអាចទាក់ទងរកជំនួយ តាមរយៈអង្គភាពពន្ធដារដែលនៅជិតលោកអ្នក។

## អាសយដ្ឋានទំនាក់ទំនង

### អគ្គនាយកដ្ឋានពន្ធដារ

ឡូត៍លេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងមៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (៨៥៥) ២៣ ៨៨៦ ៧០៨
សារអេឡិចត្រូនិក៖ info@tax.gov.kh

### នាយកដ្ឋាន សេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ

សារអេឡិចត្រូនិក៖ dtsta@tax.gov.kh

### នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ

សារអេឡិចត្រូនិក៖ dlls@tax.gov.kh

**នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ**
សារអេឡិចត្រូនិក៖ dlt@tax.gov.kh

**សាខាពន្ធដារ ខណ្ឌឬស្សីកែវ**
ផ្ទះលេខ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ russeykeo@tax.gov.kh

**សាខាពន្ធដារ ខណ្ឌដូនពេញ**
ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ daunpenh@tax.gov.kh

**សាខាពន្ធដារ ខណ្ឌ៧មករា**
ផ្ទះលេខ២៥បេ ផ្លូវសម្តេចប៉ាន(២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ 7makara@tax.gov.kh

**សាខាពន្ធដារ ខណ្ឌមានជ័យ**
អគារលេខ៣៤សេ ផ្លូវ៣៦១កែង៦៤២ សង្កាត់ច្បារអំពៅ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ meanchey@tax.gov.kh

**សាខាពន្ធដារ ខណ្ឌចំការមន**
ផ្ទះលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ chamkarmorn@tax.gov.kh

## សាខាពន្ធដារ ខណ្ឌទួលគោក

ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានី ភ្នំពេញ

សារអេឡិចត្រូនិក៖ tuolkork@tax.gov.kh

## សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ២៣៤ ផ្លូវលេខ២០០៧ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ dangkor@tax.gov.kh

## សាខាពន្ធដារ ខេត្តកណ្ដាល

ផ្ទះលេខ១០៣ ផ្លូវលេខ១០៨ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

សារអេឡិចត្រូនិក៖ kandal@tax.gov.kh

## សាខាពន្ធដារ ខេត្តកំពង់ចាម

ផ្ទះលេខ៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម

សារអេឡិចត្រូនិក៖ kampongcham@tax.gov.kh

## សាខាពន្ធដារ ខេត្តបាត់ដំបង

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

សារអេឡិចត្រូនិក៖ battambang@tax.gov.kh

## សាខាពន្ធដារ ខេត្តព្រៃវែង

ភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

សារអេឡិចត្រូនិក៖ preyveng@tax.gov.kh

### សាខាពន្ធដារ ខេត្តសៀមរាប

ផ្លូវជាតិលេខ៦ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប

សារអេឡិចត្រូនិក៖ siamreap@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ធំ

ផ្លូវលេខ៦ ភូមិត្រឡាំងលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

សារអេឡិចត្រូនិក៖ kampong_thom@tax.gov.kh

### សាខាពន្ធដារ ខេត្តតាកែវ

ផ្លូវលេខ៣ ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

សារអេឡិចត្រូនិក៖ takeo@tax.gov.kh

### សាខាពន្ធដារ ខេត្តស្វាយរៀង

ផ្លូវភូមិរោងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង

សារអេឡិចត្រូនិក៖ svayrieng@tax.gov.kh

### សាខាពន្ធដារ ខេត្តពោធិ៍សាត់

ផ្លូវជាតិលេខ៥ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

សារអេឡិចត្រូនិក៖ pursat@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង

ភូមិឃ្លាំងប្រាក់ ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

សារអេឡិចត្រូនិក៖ kampongchhnang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

សារអេឡិចត្រូនិក៖ kampongspeu@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពត**

ភូមិ១ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

សារអេឡិចត្រូនិក៖ kampot@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះសីហនុ**

ផ្លូវ២៨មិថុនា សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

សារអេឡិចត្រូនិ៖ preahsihanouk@tax.gov.kh

**សាខាពន្ធដារ ខេត្តកោះកុង**

ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

សារអេឡិចត្រូនិក៖ kohkong@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះវិហារ**

ភូមិកណ្ដាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

សារអេឡិចត្រូនិក៖ preahvihear@tax.gov.kh

**សាខាពន្ធដារ ខេត្តក្រចេះ**

ផ្ទះលេខ៧៣ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ

សារអេឡិចត្រូនិក៖ kratie@tax.gov.kh

**សាខាពន្ធដារ ខេត្តរតនៈគិរី**

ផ្លូវភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនៈគិរី

សារអេឡិចត្រូនិក៖ ratanakiri@tax.gov.kh

**សាខាពន្ធដារ ខេត្តមណ្ឌលគិរី**

ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

សារអេឡិចត្រូនិក៖ mondulkiri@tax.gov.kh

**សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ**

ប្លុកU ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ
ខេត្តបន្ទាយមានជ័យ

សារអេឡិចត្រូនិក៖ banteaymeanchey@tax.gov.kh

**សាខាពន្ធដារ ខេត្តស្ទឹងត្រែង**

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

សារអេឡិចត្រូនិក៖ stoengtreng@tax.gov.kh

**សាខាពន្ធដារ ខេត្តកែប**

ផ្លូវ៣៣A ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប

សារអេឡិចត្រូនិក៖ kep@tax.gov.kh

**សាខាពន្ធដារ ខេត្តប៉ៃលិន**

ភូមិបឱនាវ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន

សារអេឡិចត្រូនិក៖ pailin@tax.gov.kh

**សាខាពន្ធដារ ខេត្តឧត្តរមានជ័យ**

ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

សារអេឡិចត្រូនិក៖ odormeanchey@tax.gov.kh